**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :..........០១៣/២២..........ក.ប/ស.ក្ល.ណា.ម.ក

# សេចក្តីជូនដំណឹង

## ស្តីពី

## ការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន សម្រាប់ពលករជំនាញផ្នែកថែទាំ ដើម្បីទៅធ្វើការនៅប្រទេសជប៉ុន

យោងតាមការជូនដំណឹងពីក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២២ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជូនដំណឹងដល់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងសាធារណជនដែលមានបំណងទៅធ្វើការនៅប្រទេសជប៉ុន ក្នុងគម្រោងពលករជំនាញ ឱ្យបានជ្រាបថាអង្គភាពទទួលបន្ទុកការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន នឹងរៀបចំការធ្វើតេស្តភាសា និងតេស្តជំនាញ តាមរយៈប្រព័ន្ធកុំព្យូទ័រ (CBT) ក្នុងគម្រោងពលករជំនាញ សម្រាប់ផ្នែកថែទាំ (Nursing) ដែលមានព័ត៌មានលម្អិត ដូចខាងក្រោម៖

| ល.រ | ប្រភេទតេស្ត | កាលបរិច្ឆេទធ្វើតេស្ត | មណ្ឌល | តម្លៃចុះឈ្មោះ |
|---|---|---|---|---|
| ១ | ផ្នែកថែទាំ | ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២២<br>ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២២ | សកលវិទ្យាល័យអន្តរជាតិប៊ែលធី (សាខាទួលស្លែង) | ១៨ដុល្លារ |
| | | ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ | វិទ្យាស្ថានអភិវឌ្ឍន៍វិស័យអប់រំ (EDI) | |

- លក្ខខណ្ឌចុះឈ្មោះធ្វើតេស្តជំនាញ និងតេស្តភាសាគឺចាប់ពីអាយុ ១៧ឆ្នាំឡើងទៅ ដោយមិនគិតពីកម្រិតវប្បធម៌
- សម្រាប់ព័ត៌មានលម្អិត និងការចុះឈ្មោះ សូមចូលមើលគេហទំព័រ http://ac.prometric-jp.com/testlist/nc/en/index.html ឬទំនាក់ទំនងតាមលេខទូរស័ព្ទ +855 10 568 383/ +855 17 571 177/ +855 97 767 0033 រៀងរាល់ម៉ោងធ្វើការ
- ព័ត៌មានមណ្ឌលសម្រាប់ធ្វើតេស្តមានដូចខាងក្រោម៖
  ១. សកលវិទ្យាល័យអន្តរជាតិ ប៊ែលធី (សាខាទួលស្លែង)
    - អាសយដ្ឋាន៖ ផ្ទះលេខ២១ ផ្លូវលេខ៣៦០ សង្កាត់បឹងកេងកង៣ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
    - លេខទូរស័ព្ទ៖ +855 78 221 222
  
  ២. វិទ្យាស្ថានអភិវឌ្ឍន៍វិស័យអប់រំ (EDI)
    - អាសយដ្ឋាន៖ ផ្ទះលេខ៩A ផ្លូវលេខ៣៧០ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ
    - លេខទូរស័ព្ទ៖ +855 12 629 768 / +855 15 729 123
- សេវានៃការចុះឈ្មោះធ្វើតេស្តគឺបង់ជូនទៅអង្គភាពទទួលបន្ទុកការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន
- ឯកសារចាំបាច់ដែលត្រូវយកមកជាមួយនៅថ្ងៃធ្វើតេស្ត៖ អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ឬប័ណ្ណបើកបរ

បញ្ជាក់៖ កាលបរិច្ឆេទនៃការធ្វើតេស្តនេះ អាចនឹងផ្លាស់ប្តូរអាស្រ័យទៅតាមស្ថានភាពជំងឺកូវីដ-១៩។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងសាធារណជនដែលមានបំណងចង់ចុះឈ្មោះធ្វើតេស្តភាសា និងតេស្តជំនាញសម្រាប់ផ្នែកថែទាំ ជ្រាបតាមការគួរ។

ថ្ងៃ អង្គារ ១៦កើត ខែ ជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០២២

រដ្ឋមន្ត្រី

**អ៊ិត សំហេង**

**<u>ចម្លងជូន</u>**

-សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា(ACRA)
-សមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា(MAC)
-ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់
"ដើម្បីជួយផ្សព្វផ្សាយ និងសហការ"
-ឯកសារ-កាលប្បវត្តិ